**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**


លេខ ១០៧៣ អ.ន.ក

ថ្ងៃ អង្គារ ៤ កើត ខែ ភទ្របទ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៨

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែសីហា ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបនូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំខែសីហា ឆ្នាំ២០១៨ មានដូចខាងក្រោម៖

## I.<u>សភាពការណ៍រួម</u>

នៅក្នុងខែសីហាឆ្នាំ២០១៨កន្លងទៅនេះ អាកាសធាតុក្តៅ និងមានភ្លៀងធ្លាក់ច្រើនរាយប៉ាយស្ទើរគ្រប់តំបន់ ហើយបានបង្កជាជំនន់ទឹកភ្លៀង និងទឹកទន្លេ នៅតាមបណ្តាខេត្ត-រាជធានីមួយចំនួន ។ ចំពោះការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៨ កសិករនៅតាមបណ្តាខេត្ត-រាជធានីបាននិងកំពុងបន្តភ្ជួររាស់ សាបសំណាប ស្ទូង និងព្រោះស្រូវគ្រប់ប្រភេទដោយសម្រេចបានលើផ្ទៃដីចំនួន ២.៤៩៦.៣២២ហ.ត ស្មើនឹង៩៩,៣០% នៃផែនការចំនួន ២.៥១៣.៨៩៥ហ.ត លឿនជាងឆ្នាំមុនចំនួន ៤៥.៣២២ហ.ត។ ដំណាំរួមផ្សំអនុវត្តបានចំនួន ៣២.៨៧៥ហ.ត លឿនជាងឆ្នាំមុនចំនួន ៩៥៧ហ.ត និងដំណាំឧស្សាហកម្មអនុវត្តបានចំនួន ៨០៥.៥៦៧ហ.ត យឺតជាងឆ្នាំមុនចំនួន ៣.៧៣៧ហ.ត។ បច្ចុប្បន្នមានខេត្តចំនួនបី បានបញ្ចប់ល្បឿនបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៨ រួមមានខេត្តបន្ទាយមានជ័យ ស្ទឹងត្រែង និងខេត្តឧត្តរមានជ័យ។

ផ្ទៃដីដំណាំស្រូវរងផលប៉ះពាល់ដោយជំនន់ទឹកភ្លៀង និងទឹកទន្លេមេគង្គ នៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពត កណ្តាល កោះកុង ក្រចេះ រាជធានីភ្នំពេញ ព្រះវិហារ ព្រៃវែង រតនគិរី សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ស្វាយរៀង តាកែវ កែប និងខេត្តត្បូងឃ្មុំមានចំនួនសរុប ៧១.៥៥១ហ.ត ខូចខាតចំនួន ២៤.៩៥២ហ.ត ចំណែកដំណាំរួមផ្សំ និងឧស្សាហកម្មរងផលប៉ះពាល់សរុបចំនួន ៩.៥៧៤ហ.ត និងខូចខាតចំនួន ២.៩៧៥ហ.ត។ ផ្ទៃដីដំណាំស្រូវរងផលប៉ះពាល់ដោយគ្រោះរាំងស្ងួត នៅខេត្តបន្ទាយមានជ័យ បាត់ដំបង កណ្តាល ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង និងខេត្តប៉ៃលិន សរុបចំនួន ៦៧.៩២៩ហ.ត ខូចខាតសរុបចំនួន ៣.៣១៨ហ.ត ចំណែកដំណាំរួមផ្សំ និងឧស្សាហកម្មរងផលប៉ះពាល់សរុបចំនួន ១១ហ.ត។

## II.**លទ្ធផលបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៨** (គិតត្រឹមថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨)

**១. ដំណាំស្រូវ** : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ២.៤៩៦.៣២២ ហ.ត ស្មើនឹង៩៩,៣០ % នៃផែនការចំនួន ២.៥១៣.៨៩៥ ហ.ត លឿនជាងឆ្នាំមុនចំនួន ៤៥.៣២២ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន ២.៧៦៤.៦៧៦ហ.ត លឿនជាងឆ្នាំមុនចំនួន ១៤.៩៩៦ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន២.៦៥៩.៤០៧ ហ.ត ស្មើនឹង៩៦,១៩% នៃផ្ទៃដីភ្ជួររាស់សរុប
- ផ្ទៃដីសាបសរុប : ៣២.១៣៧ហ.ត យឺតជាងឆ្នាំមុនចំនួន ៧.៦៧២ហ.ត។




អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427